# មជ្ឈមណ្ឌលឯកសារកម្ពុជា

## ករណី ភន ហឿន I 10059

## សម្ភាសជាមួយ ឯក ហេន អាយុ៤៧ឆ្នាំ ត្រូវជាប្អូនស្រី

## នៅភូមិអន្តរជ័យក្រោម ឃុំមហាខ្ញូង ស្រុកកោះសូទិន ខេត្តកំពង់ចាម

## សម្ភាសន៍ ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៣

## សម្ភាសដោយៈ ឡុង ដានី

ដានីៈ មីងមានឈ្មោះអីដែរ?

ហេនៈ ឈ្មោះហេន ។

ដានីៈ ត្រកូល?

ហេនៈ ឈ្មោះឯក ។

ដានីៈ ឯកហេន?

ហេនៈ ចា ។

ដានីៈ សព្វថ្ងៃមីងមានអាយុប៉ុន្មានដែរ?

ហេនៈ អាយុ៤៧ ។

ដានីៈ មានស្រុកកំណើតកើតជានៅក្នុង ភូមិឃុំ ស្រុកអីដែរ?

ហេនៈ នៅភូមិអន្តរជ័យ ឃុំមហាខ្ញូង ស្រុកកោះសូទិន ។

ដានីៈ ចុះសព្វថ្ងៃណឹងមីងនៅក្នុងភូមិ ឃុំ ស្រុកអីទៅ?

ហេនៈ នៅក្នុងភូមិអន្តរជ័យ ឃុំមហាខ្ញូង ស្រុកកោះសូទិន ។

ដានីៈ អន្តរជ័យក្រោម?

ហេនៈ បាទអន្តរជ័យក្រោម ។

ដានីៈ ចុះមីងមានគ្រួសារឈ្មោះដែរ?

ហេនៈ ឈ្មោះសុង ផល ។

ដានីៈ សព្វថ្ងៃគាត់អាយុប៉ុន្មាន?

ហេនៈ អាយុ៤៨ ។

ដានីៈ សព្វថ្ងៃណឹងមីងមានកូនចៅទាំងអស់ប៉ុន្មាននាក់ដែរ?

ហេនៈ  មានកូនបួននាក់ ។

ដានីៈ  ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ហេនៈ  ស្រីបី ប្រុសមួយ ។

ដានីៈ  ចុះមីងមានឪពុកឈ្មោះអីដែរ?

ហេនៈ  ឈ្មោះភន ។

ដានីៈ  គាត់ស្លាប់ពីជំនាន់ណាដែរ?

ហេនៈ  គាត់ស្លាប់ពីជំនាន់សង្គ្រាម ។

ដានីៈ  តាំងពី?

ហេនៈ  តាំងពីរដ្ឋប្រហារហើយឆ្នាំ៧០គត់ ។

ដានីៈ  គាត់ស្លាប់ដោយសារមូលហេតុអីដែរ?

ហេនៈ  ត្រូវគ្រាប់បែក ។

ដានីៈ  ត្រូវគេផ្លោងគ្រាប់បែក?

ហេនៈ  ចាស ។

ដានីៈ  ចុះម្តាយមីង?

ហេនៈ  ម្តាយខ្ញុំគាត់នៅរស់ ។

ដានីៈ  សព្វថ្ងៃគាត់អាយុប៉ុន្មានហើយ?

ហេនៈ  ៧៥ ។

ដានីៈ  សព្វថ្ងៃគាត់រស់នៅឯណាទៅ?

ហេនៈ  គាត់រស់នៅអន្លង់វែងជ័យណឹងដែរ តែគាត់ទៅលេងចៅនៅអ្នកលឿង ។

ដានីៈ  ទៅលេងចៅនៅអ្នកលឿង?

ហេនៈ  ចាស ។

ដានីៈ  សព្វថ្ងៃណឹងមីងប្រកបមុខរបបរកស៊ីធ្វើអីដែរ?

ហេនៈ  អត់មានធ្វើអីផង កូនចេញទៅរកស៊ីធ្វើការនៅរោងចក្រកាត់ដេរ ។

ដានីៈ  មីងមានបងប្អូនបង្កើតទាំងអស់ប៉ុន្មាននាក់ ទាំងបាត់ទាំងនៅ?

ហេនៈ  ទាំងអស់បី បាត់អស់ពីរ ។

ដានី៖ អីចឹងមីងមានបងប្អូនទាំងអស់បីនាក់ បាត់ពីរនៅសល់តែម្នាក់?

ហេន៖ ចា ។

ដានី៖ បាត់ពីរណឹងឈ្មោះអីខ្លះទៅ?

ហេន៖ ឈ្មោះហឿនមួយ ឈ្មោះហៃមួយ ។

ដានី៖ ស្រីរឺប្រុស?

ហេន៖ ប្រុសទាំងពីរ ។

ដានី៖ ចុះឈ្មោះហឿនណឹងគាត់ជាកូនទីប៉ុន្មានដែរ?

ហេន៖ គាត់ជាកូនទី១ ។

ដានី៖ តាមមីងចាំគាត់កើតឆ្នាំអីដែរ?

ហេន៖ ឆ្នាំម្សាញ់ ។

ដានី៖ បងមីងប៉ុន្មានឆ្នាំ?

ហេន៖ ឆ្នាំម្សាញ់ ខ្ញុំឆ្នាំរកា ។

ដានី៖ គាត់ស្រុកកំណើតកើតជាគាត់នៅកន្លែងណាដែរ?

ហេន៖ គាត់កើតនៅអន្លុរជ័យណឹងដែរ ។

ដានី៖ ចុះកាលពីក្មេងៗគាត់បានរៀនសូត្រអីដែរ?

ហេន៖ កាលពីក្មេងៗគាត់មិនបានរៀនសូត្រនៅភូមិអន្លុរជ័យណឹងទេ ។

ដានី៖ គាត់ទៅរៀននៅឯណា?

ហេន៖ គាត់ទៅរៀននៅខាងត្នោត ស្វាយទាប ។

ដានី៖ ចុះគាត់ឈប់រៀននៅក្នុងឆ្នាំណា?

ហេន៖ ខ្ញុំអត់បានដឹងដែរព្រោះនៅបែក ។

ដានី៖ គាត់ចេញទៅធ្វើកងទ័ព?

ហេន៖ គាត់ចេញទៅនៅឆ្នាំ៧៣ ។

ដានី៖ មូលហេតុអីបានគាត់ចេញទៅ?

ហេន៖ ខ្ញុំអត់ដឹងដែរកាលណឹង ព្រោះនៅបែកគ្នាកាលណឹងកំព្រើកំព្រាអត់ពីឪពុកទៅ ទាំងពីរនាក់បងប្អូនចូលទៅក្នុងទាំងពីរនាក់បងប្អូន ។

ដានី៖ នៅទាំងពីរនាក់បងប្អូនចូលទៅជាមួយគ្នា?

ហេន៖ ចូលទៅជាមួយគ្នា ។

ដានី៖ កាលណឹងគាត់ចូលកងទ័ពនៅខាងខ្មែរក្រហមណឹងនៅភូមិឯណោះ?

ហេន៖ នៅ៣០៤ខាងភូមិភាគឧត្តរ ។

ដានី៖ នៅ៣០៤ ចូលពីកន្លែងណាទៅ?

ហេន៖ ចូលពីខាង... ។

ដានី៖ ពេលដែរគាត់កងទ័ពហើយណឹងគាត់ដែរមកលេងផ្ទះមកអីទេ?

ហេន៖ មកជួនកាលមួយខែមកម្តង ជួនកាលពីរបីខែបានមកម្តង ។

ដានី៖ ចុះពេលគាត់មកគាត់មាននិយាយប្រាប់រឿងរាវប្រាប់ម្តាយប្រាប់អីទេ?

ហេន៖ អត់ដែរនិយាយអីផង ។

ដានី៖ គាត់អត់មានប្រាប់ថាគាត់ទៅធ្វើកងទ័ពខាងណា នៅកន្លែងណាអីទេ?

ហេន៖ កាលណឹងគាត់ប្រាប់ដែរតែខ្ញុំវាភ្លេចទៅ ខ្ញុំនៅតូចៗស្ទើរណាស់រកចាំមិនបាន ។

ដានី៖ ពេលគាត់មកលេងម្តងៗគាត់មកម្នាក់ឯង រឺមានមិត្តភក្រមកជាមួយ?

ហេន៖ ជួនកាលមកពីរនាក់ ជួនកាលមកម្នាក់ឯង ។

ដានី៖ អីចឹងខស្បៀហ៍មកលេងដែរ?

ហេន៖ ខស្បៀហ៍មកលេង ។

ដានី៖ កាលគាត់មកលេងណឹងគាត់ជិះអីមក?

ហេន៖ ជួនកាលម៉ូតូ ជួនកាលក៏កង់ ។

ដានី៖ ចុះគាត់មកលេងម្តងៗគាត់មកលេងបានប៉ុន្មានថ្ងៃ?

ហេន៖ ជួនកាលដេកមួយយប់អីណឹង អត់ហានទៅយូរទេ ។

ដានី៖ ពេលបែកឆ្នាំ៧៩ហើយណឹងដឹងថាគាត់ទៅនៅឯណាដែរ?

ហេន៖ គ្រាន់តែដឹងដំណឹងថាគាត់នៅភ្នំពេញ ហើយខ្ញុំណឹងនៅភ្នំពេញដែរតែមិនបានជួបគ្នាសោះ នៅកន្លែងផ្សេងគ្នា ។

ដានី៖ កាលគាត់នៅភ្នំពេញណឹង មីងដឹងថាគាត់នៅអង្គភាពណាដែរ?

ហេន៖ អត់ដឹងដែរ ។

ដានី៖ ចុះកាលនៅភ្នំពេញណឹងមីងអត់មានដើររកគាត់ទេ?

ហេន៖ អត់មានដើរទេ នៅកន្លែងណានៅកន្លែងណុង បងប្អូនមិនអាចស្កាត់ជួបគ្នាបានទេ ធ្វើការកន្លែងផ្សេងគ្នា ។

ដានី៖ ពេលគាត់ទៅនៅភ្នំពេញហើយគាត់មានដែរមកលេងស្រុកកំណើតទេ?

ហេន៖ មកតែម្តងហើយទៅវិញបាត់សូន្យ ។

ដានី៖ មកក្នុងឆ្នាំណាដែរ?

ហេន៖ មកនៅក្នុងឆ្នាំ៧៥ណឹងតែម្តង ៧៦, ៧៧បាត់រហូត ។

ដានី៖ ពេល៧៦, ៧៧ណឹងមីង ឪពុកម្តាយអីលែងដឹងដំណឹងពីគាត់ហើយ?

ហេន៖ អត់បាត់រហូត ។

ដានី៖ ចុះក្រោយមកដល់ពេលឆ្នាំ៧៩ បែកមកមានដែរដឹងដំណឹងពីគាត់ដែរ?

ហេន៖ អត់បាត់រហូតដល់សព្វថ្ងៃនេះ ។

ដានី៖ ចុះមីងម្តាយមីងអីមានដែរទៅស៊ើបដំណឹងពីគាត់ដែរ?

ហេន៖ ស៊ើបមិនដឹងជាស៊ើបពីណាវាមិនដឹងពីដឹង ពីណាស្គាល់នៅឯណាអីផង ។

ដានី៖ ចុះមកដល់សព្វថ្ងៃណឹងមីងនៅមានសង្ឃឹមថាគាត់នៅរស់ដែរ?

ហេន៖ ដូចមិនសូវមានសង្ឃឹម ៗតិចណាស់ ភាគច្រើនអត់សង្ឃឹមទេព្រោះអីកាលសម័យណឹងវាបាត់អត់ដឹងដំណឹង?

ដានី៖ ចុះមកដល់រាល់ថ្ងៃណឹងមីងនៅនឹករលឹកគាត់អត់?

ហេន៖ នៅៗតែនឹក ។

ដានី៖ ជាពិសេសមីងឧស្សាហ៍នឹកគាត់នៅពេលណា ដូចជានៅពេលមីងសម្រាន ពេលបុណ្យទានជួបជុំបងប្អូន?

ហេន៖ នឹកដូនកាលមានបុណ្យទាន គេមានបងប្អូនច្រើនខ្ញុំមានតែឯងមានតែកូនចៅប្តីប្រពន្ធ ។

ដានី៖ ចុះពេលមីងនឹកឃើញដល់គាត់អីចឹង ដើម្បីធ្វើឲ្យរំសាយចិត្តកុំឲ្យនឹកដល់គាត់ទៀត?

ហេន៖ វាតែខំរកស៊ីចិញ្ចឹមកូនចិញ្ចឹមចៅទៅ ។

ដានី៖ ពេលមីងនឹកឃើញគាត់ តើវិធីណាដើម្បីកាត់បន្ថយការនឹករលឹកដើម្បីឲ្យសប្បាយចិត្តទៅវិញ?

ហេនៈ មានតែការកាត់ចិត្ត ។

ដានីៈ កាត់យ៉ាងម៉េចទៅ?

ហេនៈ អើយ! បើរស់ឃើញមកហើយ បើស្លាប់មិនដឹងធ្វើម៉េចទេគិតថាអីចឹង ។

ដានីៈ ចុះមកដល់សព្វថ្ងៃណឹងមីងមាននៅសល់រូបថតរបស់គាត់ទេ?

ហេនៈ អត់មានសោះ អត់មាន ។

ដានីៈ គាត់អត់ដែរថតទេ?

ហេនៈ គាត់ថតយកមកដែរប៉ុន្តែកាលណឹងខ្ញុំនៅក្មេង ខ្ញុំចេញពីផ្ទះទៅអាអ្នកនៅផ្ទះវាទុកទៅវាខូចអស់ទៅ រូបថតគាត់ច្រើនដែរណឹង ។

ដានីៈ ចុះបងមីងម្នាក់ទៀតឈ្មោះហៃនោះ?

ហេនៈ ឈ្មោះហៃណឹងបាត់ដំណឹងសូន្យមុនណឹងទៀតនោះ គាត់មកប្រាប់ថាស្លាប់ហើយ ។

ដានីៈ បងមីងឈ្មោះអឿនមកប្រាប់ថាស្លាប់?

ហេនៈ ចាំគាត់មកប្រាប់ ។

ដានីៈ ចុះមីងជំនាន់ពី៧៥ដល់៧៩ មីងធ្វើអីដែរ?

ហេនៈ ខ្ញុំកម្មករកាត់ដេរ ។

ដានីៈ កាត់ដេរនៅកន្លែងណា?

ហេនៈ នៅអូរឫស្សី ។

ដានីៈ កាលណឹងកម្មករកាត់ដេរនៅអូរឫស្សី ប្រធានមីងដំបូងឈ្មោះអីដែរ?

ហេនៈ ឈ្មោះកែវ ។

ដានីៈ គាត់អ្នកស្រុកយើងណឹងដែរ?

ហេនៈ គាត់មិនដឹងមកពីខាងណាដែរ ប៉ុន្តែកាលណឹងគេបញ្ជូនពួកខ្ញុំចូលជាមួយគេធ្វើការជាមួយគេនៅអូរឫស្សី ។

ដានីៈ កាលណឹងហេតុអីបានចូលទៅធ្វើការកាត់ដេរនៅអូរឫស្សី?

ហេនៈ មុនដំបូងគេឲ្យទៅលើកទំនប់វែកដីឡើងទំនប់ ហើយខ្ញុំនៅតូចដែរវែកដីក៏មិនបាននិងគេតគេះតគាស់ទៅបានបីថ្ងៃក៏គេរើសទៅយុទ្ធនារីណឹងក៏ប្រថុយទៅ ស្លាប់ក៏ស្លាប់ទៅ ទៅតែម្តង ។

ដានីៈ កាលនោះមីងអាយុប៉ុន្មាន កាលគេរើសទៅយុទ្ធនារី?

ហេនះ  អាយុ១៦  ១៧ឆ្នាំ ។

ដានី:  កាលណឹងមីងទៅម្នាក់ឯង រឺមានអ្នកនៅក្នុងភូមិគេទៅជាមួយដែរ?

ហេនះ  ទៅម្នាក់ឯងនៅក្នុងភូមិខ្ញុំទៅតែឯងដល់អន្លុងដ័យ លើទៅម្នាក់ដែរបានពីរនាក់ ។

ដានី:  កាលទៅដំបូងទៅនៅឯណា?

ហេនះ  ទៅនៅស្រុកនៅជីហែ  ចេញពីជីហែទៅនៅស្រុកកញ្ជ្រៀចឯនោះ ។

ដានី:  បន្ទាប់មកទៀត?

ហេនះ  ទៅហាត់ទាហានយុទ្ធនារីកាលណឹងកាន់កាំភ្លើងអីនឹងគេដែរណឹង  ដល់ហាត់ចេះគេបញ្ជូនទៅភ្នំពេញ ដល់ចេះហើយចប់បណ្តោយ ។

ដានី:  អត់បានវៃ?

ហេនះ  ចា!  អត់បានវៃបានតែហាត់ ។

ដានី:  ចុះការងារកាត់ដេរនៅភ្នំពេញយ៉ាងម៉េចដែរ?

ហេនះ  ងើបពីម៉ោងបួនទៅស្រោចបន្លែមួយសារមកដល់ផ្ទះវិញម៉ោង៧ចូលដេរ  ម៉ោងម៉ាដណ្តប់ឈប់ហូបបាយហើយម៉ោងមួយចូលដេរដល់ម៉ោងបួនណឹងឈប់ទៅពលកម្មទៀត  ម៉ោង៥មកវិញហូបបាយ  ម៉ោងប្រាំមួយចូលដេរម៉ាសារទៀតម៉ោង៩បានឈប់ ។

ដានី:  ចុះការកាត់ដេរនៅភ្នំពេញការហូបចុកអីគ្រប់គ្រាន់ដែរ?

ហេនះ  អត់ទេខ្វះខាត  ប៉ះពេលណាគេឲ្យនំប៉័ងម៉ាកំណាត់ម្នាក់អីទៅ  ប៉ះពេលណាគេស្ងោត្រកួន ។

ដានី:  កាលណឹងបានហូបនំប៉័ងដែរ?

ហេនះ  ហូបនំប៉័ងម៉ាកំណាត់ ។

ដានី:  កាលណឹងមានដែរ?

ហេនះ  មានដែរ  ត្រូវគេឲ្យហូបនំប៉័ងអីចឹងមួយពីនាក់ៗ ។

ដានី:  គេអត់ឲ្យហូបបាយទេ?

ហេនះ  ជួនណាគេហូបបាយទៅ  ប៉ះខែណាអត់អីចឹងគេឲ្យនំប៉័ងហូបអីចឹងទៅ  ជួនណាដំឡូងគរស្ងោអីចឹងទៅអីចឹង  ជួនណាពោតក្រហមយើងណឹងស្ងោរចែកម្នាក់បីអីចឹងទៅ ។

ដានី:  អីចឹងមីងធ្វើកម្មកការកាត់ដេរនៅភ្នំពេញរយៈពេលប៉ុន្មានដែរ?

ហេនះ  តាំងពីទៅរហូត  រហូតដល់ចេញពីភ្នំពេញថ្ងៃទី៧មករា ។

ដានី៖ កាលនោះប្រធាននៅកន្លែងកាត់ដេរអីចឹងផ្លាស់ប្តូរប៉ុន្មាននាក់?

ហេន៖ ផ្លាស់មុនដំបូងនារីកែវអីចឹង តែមិនដឹងថានៅភូមិភាគណាទេគាត់ គេចាប់អស់ម៉ាអីចឹងទៅ បានចូលពួកនិរតីមក ។

ដានី៖ ឈ្មោះអីទៅពួនិរតីហ្នឹង?

ហេន៖ និរតីមកឈ្មោះខន ។

ដានី៖ ចុះមីងស្គាល់ពីណាអ្នកធំដូចថាមកទាក់ទងកន្លែងកាត់ដេរអី?

ហេន៖ ធ្លាប់ចូលសាលារៀនសូត្រ?

ដានី៖ បាទ?

ហេន៖ ស្គាល់តាខៀវ សំផន នួន ជា អីសុទ្ធធ្លាប់រៀនជាមួយគាត់ ។

ដានី៖ រៀនពីអីទៅ?

ហេន៖ រៀនអប់រំពីការរស់នៅ ពីសីលធម៌រស់នៅឲ្យព្យាយាមតស៊ូ ។

ដានី៖ យ៉ាងម៉េចគាត់អប់រំយើង?

ហេន៖ ឲ្យយើងចេះតស៊ូធ្វើការតាមពេលវេលាម៉ោងកុំខ្ជិលច្រអូស ។

ដានី៖ កាលហ្នឹងមីងដឹងថាខៀវ សំផន នួន ជា កាន់ខាងណាដែរ?

ហេន៖ អត់ដឹងដែរ ប៉ុន្តែកាលហ្នឹងគេហៅទៅរៀននៅបុរីកីឡា បុស្តិ៍លេខ៥រាល់ថ្ងៃសាលាខ្ញុំរៀន ។

ដានី៖ សាលាអីទៅ?

ហេន៖ សាលារៀនអប់រំកម្មករកាត់ដេរ ។

ដានី៖ កាលហ្នឹងកម្មករកាត់ដេរប្រហែលប៉ុន្មាននាក់?

ហេន៖ ប្រហែល៨០០,៩០០នាក់ ។

ដានី៖ អីចឹងនារីកែវហ្នឹងគ្រប់គ្រងកម្មករ៨០០, ៩០០នាក់ហ្នឹង?

ហេន៖ ចាស ។

ដានី៖ ចុះមានដែរខៀវ សំផន, នួន ជា ចុះអ្នកផ្សេងទៀត?

ហេន៖ មានតាប៉ន់ នៅមន្ទីរ៨៧០ ។

ដានី៖ គាត់ឈ្មោះតាប៉ន់ មន្ទីរ៨៧០?

ហេន៖ ចាស ។

ដានីៈ គាត់មកបង្រៀននៅណឹងដែរ?

ហេនៈ ចាស ។

ដានីៈ គាត់បង្រៀនរឿងអី?

ហេនៈ បង្រៀនពីរឿងធ្វើការតស៊ូ កុម្មុយនីស្តអីចឹងទៅ មានអីខ្លះទៀតតែខ្ញុំភ្លេចអស់ហើយ ។

ដានីៈ ចុះពេលដែរថាឈ្មោះខៀវ សំផន, នួន ជា ឈ្មោះប៉ង់ អីមកបង្រៀនរយៈពេលប៉ុន្មានគេបង្រៀនម្តង?

ហេនៈ រៀនម្តងម៉ាអាទិត្យ ។

ដានីៈ ម៉ាឆ្នាំគេរៀនប៉ុន្មានដង?

ហេនៈ ក្នុងមួយឆ្នាំគេរៀនម្តង ។

ដានីៈ ចុះប៉ង់ហេតុអីបានមិនដឹងថាគាត់ប្រធានមន្ទីរ៨៧០?

ហេនៈ គាត់មកពីណឹង ។

ដានីៈ មិនដឹងថាមន្ទីរ៨៧០ណឹងនៅកន្លែងណាដែរ?

ហេនៈ អត់ដឹង ។

ដានីៈ គាត់ប្រធានមន្ទីរ៨៧០ណឹង រឺក៏យ៉ាងម៉េច?

ហេនៈ គាត់ប្រធាន ។

ដានីៈ ចុះកាលជំនាន់ណឹងមានដឹងថាគេចាប់កម្មាភិបាលពីកន្លែងណឹងទៅ មិនមានដឹងមូលហេតុអីបានគេចាប់?

ហេនៈ អត់ដឹងដែរធ្វើការដូចគ្នា ដួនកាលគេមកហៅឡើងឡានទៅ ។

ដានីៈ កាលគេហៅណឹងមិនបានឃើញច្បាស់ផ្ទាល់ភ្នែកដែរ?

ហេនៈ ឃើញផ្ទាល់ភ្នែក ។

ដានីៈ ឃើញពីណាខ្លះ?

ហេនៈ ឃើញកែវប្រធានជំបូងណឹង ហៅចូលក្នុងឡានគេបិតខ្ទប់ទៅបាត់ ។

ដានីៈ គេហៅទៅធម្មតារឺមានការចាប់ចងដែរ?

ហេនៈ អត់ចងទេគ្រាន់តែហៅបញ្ចូលទៅបាត់ ។

ដានីៈ ចុះហេតុអីគ្រាន់តែហៅបញ្ចូនឡានមិនដឹងថាគេចាប់គាត់យកទៅ?

ហេនៈ ចុះបើឃើញទៅបាត់អត់ឃើញមកវិញអីវ៉ាន់គាត់នៅផ្ទះ នៅទាំងអស់ អត់ឃើញវិលមកវិញផង ។

ដានីៈ កាលណឹងចាប់តែនារីកែវណឹងម្នាក់ទេ?

ហេនៈ បន្តបន្ទាប់តាមខ្សែរយៈគេណឹង ។

ដានីៈ ឆ្នាំណាដែរគេចាប់?

ហេនៈ មុនដំបូងឆ្នាំ៧៦, ៧៧ណឹង ទេ៧៧, ៧៨ហើយ ។

ដានីៈ ក្រោយពីគេចាប់នារីកែវខ្សែរយៈគាត់ មានគេចាប់អ្នកធំណាផ្សេងទៀតទេ?

ហេនៈ កន្លែងណឹង?

ដានីៈ បាទ?

ហេនៈ មុនដំបូងប្រធាន អនុប្រធាន សមាជិកអីចឹងទៅ អាណឹងជំនាន់ភូមិភាគឧត្តរ ដល់ពេលចប់ភូមិភាគឧត្តរឡើងបូរព៌ាម្តង ។

ដានីៈ បូរព៌ាគេចាប់ពីណាគេ?

ហេនៈ បូរព៌ាមិនសូវមានធ្វើធំទេ ច្រើនត្រឹមកងតូច ។

ដានីៈ ចុះកាលជំនាន់ណឹងមីងស្គាល់ខៀវ សំផន នួន ជា ច្បាស់ដែរ?

ហេនៈ ស្គាល់ច្បាស់តែក្នុងសាលាអីចឹង ឃើញគាត់តែពីចម្ងាយតែមិនបានមកជិតស្និទអីទេអត់ ។

ដានីៈ ជាមួយគាត់មីងអត់បានចុះមកសួរសុខទុក្ខមកនិយាយអី?

ហេនៈ ជួនកាលកំពុងហូបបាយអីចឹងគាត់ចូលមកដែរ ។

ដានីៈ គាត់ចូលមកមាននិយាយអីថាម៉េចដែរ?

ហេនៈ គាត់ចូលមកគ្រាន់តែពិនិត្យមើលសម្ភរយើងហូបក្រែងលរខ្វះខាតអី គាត់ថាសូឲ្យបានឆ្ងាញ់ឲ្យកម្មករបានហូបអីចឹង ។

ដានីៈ ពីណាអ្នកថា?

ហេនៈ អឹ! ខៀវ សំផន ។

ដានីៈ អត់ដឹងថាគាត់មានតួនាទីអីទេ?

ហេនៈ អត់ដឹងទេ ប៉ុន្តែគាត់មកដើរមើលសូឆ្ងាញ់ៗឲ្យកម្មករយើងមានកម្លាំងធ្វើការ ។

ដានីៈ ប្រហែលប៉ុន្មានដងដែរ?

ហេនៈ គាត់ចូលផ្សារអូឬស្សីកន្លែងខ្ញុំតម្បាញគាត់ចូលពីរដង ។

ដានីៈ ចុះនួន ជា?

ហេនៈ អត់ដែរចូលទេ ប៉ុន្តែគាត់ធ្លាប់បង្រៀន ។

ដានីៈ ចុះមីងនៅកន្លែងផ្សារអូរឫស្សីរហូតរឺមានផ្លាស់ទៅណាទេ?

ហេនៈ នៅរហូតអត់មានផ្លាស់ទៅណាទេ រហូតដល់៧ មកភាតែម្តង ។

ដានីៈ ចុះកាលនួន ជា,ខៀវ សំផន អឺចូលប្រជុំនៅក្នុងឆ្នាំណាដែរ ចូលទៅមើលកម្មករគាត់ ដែរ?

ហេនៈ ឆ្នាំ៧៧ ម្តង ៧៨ម្តងទៅពីរដង ។

ដានីៈ ដល់ប្រជុំ?

ហេនៈ រៀនណឹងនៅបុរីកីឡាមាឆ្នាំម្តង ។

ដានីៈ តាំងពីឆ្នាំ៧៥មក?

ហេនៈ ពីឆ្នាំ៧៦, ៧៧ ។

ដានីៈ ចុះកាលជំនាន់មីងនៅភ្នំពេញណឹងមីងសុំគេមកលេងផ្ទះអីដែរ?

ហេនៈ សុំដែរ កាលណឹងពុថាបងជីដូនមួយខ្ញុំណឹងស្លាប់ ហើយខ្ញុំសុំយំស្រែកគេមិនឲ្យមក ។

ដានីៈ ហេតុអីបានគេមិនឲ្យមក?

ហេនៈ មុនដំបូងគេថារៀបចំតវ៉ានទៅចាំគេឲ្យទៅ កុំយំឲ្យបាត់យំ ដល់យើងបាត់យំ វាថាឈប់ឲ្យ ទៅវិញ ។

ដានីៈ អឺចឹងតាំងពីមីងទៅនៅភ្នំពេញមក មីងអត់ដែលបានត្រឡប់មកលេងផ្ទះសោះ?

ហេនៈ អត់សោះ អត់ដែលបានមកទេ ។

ដានីៈ កាលហ្នុងមីងនឹកផ្ទះអត់?

ហេនៈ នឹក!

ដានីៈ ហេតុអីបានគេមិនឲ្យយើងមកលេងផ្ទះ?

ហេនៈ មិនដឹងដែរបើសុំគេ គេមិនឲ្យមក ។

ដានីៈ មីងសុំពីណាគេ?

ហេនៈ សុំប្រធានក្រុម ប្រធានកងគេ ។

ដានី៖  ឈ្មោះអីខ្លះទៅប្រធានក្រុមប្រធានកងគេ?

ហេន៖  ប្រធានក្រុមឈ្មោះ បងឈាន ។

ដានី៖  អ្នកស្រុកណាដែរ?

ហេន៖  ឈាននៅនិរតី ។

ដានី៖  ចុះប្រធានកង?

ហេន៖  ប្រធានកងគាត់នៅនិរតីដែរ ។

ដានី៖  គាត់ឈ្មោះអីដែរ?

ហេន៖  ...

ដានី៖  អ្នកផ្សេងៗទៀត ក៏អត់បានមកលេងដែរ?

ហេន៖  អត់បានទាំងអស់ខាងបូព៌ា បើខត្តរបាន ។

ដានី៖  ហេតុអីបានគេបែងចែកអីចឹង ខត្តរបានមក អ្នកបូព៌ាអត់បានមក?

ហេន៖  អ្នកខត្តរគេដាក់ម្តងៗ៥០នាក់អីណុះ បានមកបូព៌ាអត់ ។

ដានី៖  ហេតុអី! កាលហ្នុងមីងដឹងមូលហេតុដែលគេមិនឲ្យមកលេងផ្ទះ?

ហេន៖  មូលហេតុខាងបូព៌ាកាលហ្នុងម៉ាជំនាន់មានក្បត់ គេថាបូព៌ាក្បត់ណា គេមិនឲ្យមកទេ ។

ដានី៖  ហេតុអីបានមីងដឹងថា ខាងបូព៌ាគេថាក្បត់?

ហេន៖  ចុះបើប្រាប់ គេថាបូព៌ាក្បត់ហើយ ចូលយួន ចូលអីហ្នឹង យើងអត់មានដឹងអី នៅតែមួយកន្លែងពត៌មានអីក៏យើងអត់ដឹង ។

ដានី៖  ពេលហ្នឹង ពេលដែលគេថាបូព៌ាក្បត់អីចឹង អ្នកមកពីខាងបូព៌ាអីចឹង គេតាមដាន គេម៉េចដែរ?

ហេន៖  គេតាមដានដែរ បើសិនជាយើងមានមុខការធ្វើធំអីហ្នឹង គេតាមដានយើង គេហៅយើងទៅអប់រំ បើថាយើងហ្នឹង មើលទៅយើងអត់អីទេ ស្លូតបូត ការងារទំធ្វើហ្នឹងអត់អីទេ មើលតែរាងក្រឡេះក្រឡុះបាត់ខ្លួនហើយ ។

ដានី៖  ចុះមានអ្នកដែរបាត់ខ្លួនទៅដែរអត់?

ហេន៖  មាន ។

ដានី៖  ឈ្មោះអីខ្លះទៅ?

ហេនៈ មានម្នាក់នោះ ឈ្មោះ សឿន ។

ដានីៈ ស្រី ឬប្រុស?

ហេនៈ ស្រី!

ដានីៈ បាត់ហ្នឹង បាត់ទៅខាងណាដែរ?

ហេនៈ អត់ដឹងដែរ! ស្រាប់តែយកទៅបាត់សូន្យទៅ អត់ឃើញមកវិញ ។

ដានីៈ ឆ្នាំណាគេយកទៅ?

ហេនៈ ៧៨ ។

ដានីៈ ចុះនារីកែវ គេយកទៅឆ្នាំណាដែរ?

ហេនៈ តាំងពីឆ្នាំ៧៧ ។

ដានីៈ ចុះជំនាន់ហ្នុងគេឲ្យមីងធ្វើប្រវត្តិរូបអីដែរអត់ ពេលនៅកម្មករពេងចក្រកាត់ដេរហ្នុង?

ហេនៈ ធ្វើដែរ! គេខស្សាហ៍ធ្វើ ។

ដានីៈ ពេលធ្វើម្តងៗ គេឲ្យមីងអ្នកសរសេរ ឬក៏មានគេអ្នកសរសេរ មីងនិយាយប្រាប់គេ?

ហេនៈ គេអ្នកសរសេរ មីងអ្នកនិយាយប្រាប់គេ ។

ដានីៈ ឆ្លើយប្រាប់ថាម៉េចខ្លះទៅ?

ហេនៈ ប្រាប់ភូមិកំណើតហ្នុង បងប្អូន ឪពុកម្តាយអីហ្នុង ។

ដានីៈ ចុះដល់ពេលធ្វើម្តងៗមីងនិយាយប្រាប់គេថាដូចៗមុន ហីក៏យ៉ាងម៉េច ក្នុងប្រវត្តិរូបណា?

ហេនៈ ប្រាប់គេពិតប្រាកដទៅ អត់មានឆ្លើយកុហកគេបានទេ ស្រុកកំណើតនៅឯណា ឆ្លើយថា នៅហ្នុងទៅ ។

ដានីៈ ដូចមីងនិយាយម៉េចថា មានប្រាប់គេថាម៉េចពេលណា?

ហេនៈ អាហ្នឹងដល់ពេលយើងរត់ណា យើងរកនៅបូព៌ាហ្នឹង ចាស!ដល់ពេលរត់ឆ្នាំ៧៩នេះ ។

ដានីៈ ៧៩ហើយឬ?

ហេនៈ ចាស!គេនៅរកទៀត ។

ដានីៈ គេនៅរកថា បើពួកបូព៌ាគេអត់ឲ្យទៅជាមួយគេទេ?

ហេនៈ បូព៌ាគេទុកម៉ាដុំ ។

ដានីៈ អីចឹងទៀត! ចុះមីងរៀបការជាមួយពូតាំងពីណាមក?

ហេនៈ ឆ្នាំ៧៩ ប៉ុនខែ១១ ជិតដាច់ ។

ដានី៖ អ៊ីចុង មីងមិនមែនរៀបការ កាលមីងនៅកម្មករកាត់ដេរហ្នឹង?

ហេនៈ អត់ទេ! អត់ដែរស្គាល់គ្នាផង ។

ដានី៖ ទៅស្គាល់នៅណាទៅ?

ហេនៈ ទៅស្គាល់នៅជំរុំ ។

ដានី៖ ស្គាល់គ្នានៅជំរុំ?

ហេនៈ ចាស ។

ដានី៖ ការតាមប្រពៃណីធម្មតា ឬការជាគូរដែរ?

ហេនៈ អត់ទេ! ការតែមួយគូ ស្មើរគេត្រឹមត្រូវ កាលហ្នុងអង្គការកាកបាទក្រហមគេជំនួយម្ហូបអាហារដែរ ។

ដានី៖ មីងនៅជំរំណា?

ហេនៈ មុនដំបូងបង្អស់ខ្ញុំចូលជំរំស្រះកែវ ។

ដានី៖ ក្រោយមកទៀត?

ហេនៈ ដល់ក្រោយមកទៀតគេដឹកចេញមក ខ្ញុំក៏ចេញមកហ្នឹងគេ មកនៅព្រំដែន ដល់ពេលផ្អើលនៅព្រំដែនម្ដងទៀត ខ្ញុំចូលជំរំសាយអេក ។

ដានី៖ អ៊ីចឹងមីងបានវិលត្រឡប់មកផ្ទះវិញឆ្នាំណា?

ហេនៈ ក្នុងឆ្នាំ៩៣ ។

ដានី៖ ដោយសារមីងធ្លាប់បានរស់នៅ ធ្លាប់បានឆ្លងកាត់របបខ្មែរក្រហមអ៊ីចឹង មីងយល់ថារបបខ្មែរក្រហមជារបបយ៉ាងម៉េចដែរ?

ហេនៈ ពិបាកណាស់ ។

ដានី៖ ពិបាកយ៉ាងម៉េច?

ហេនៈ យើងរស់នៅទល់តែមើលគេមើលឯង គេមានអីមានហ្នឹង នឹងគេទៅ រកស៊ីនឹងគេនឹងឯងទៅ ។

ដានី៖ យល់ថាការរស់នៅ កាលមីងធ្វើកម្មករកាត់ដេរអីហ្នុងជីវិតមីងដូចថាធ្វើការក្នុងរបបហ្នឹងស្រួលឬក៏ពិបាកមីង?

ហេនៈ មិនស្រួលទេ យ៉ាប់ដែរ យប់ទល់ម៉ោង៩អីណុះបានឈប់ ។

ដានី: យ៉ាងម៉េចទៀតទៅ?

ហេនៈ គ្មានពេលទំនេរមកបានអង្គុយលេងអីទេ គ្មានទេ ងើបតាំងពីម៉ោង៤ទៅស្រោចបន្លែ មកពីស្រោចបន្លែវិញចូលដេរ ម៉ោង១១បានឈប់ ហូបបាយហើយម៉ោង១ចូលទៀត ហ្នឹងដល់ល្ងាចឈប់ទៅពលកម្មហើយមកពលកម្មហូបបាយរួចហ្នឹងចូលដេរទៀតដល់ម៉ោង៩ ។

ដានី: បាទ!កាលមីងរស់នៅជាកម្មករកាត់ដេរអីចឹងមីងជឿថាកាលជំនាន់ហ្នឹងមានការចាប់មនុស្សចាប់អីយកទៅសម្លាប់ដែរអត់?

ហេនៈ ជឿថាមាន ព្រោះយកទៅបាត់សូន្យៗអីចុង ចេះតែខ្លាចដែរ ។

ដានី: មីងជឿថាមានការកាប់សម្លាប់ដែរកាលជំនាន់ហ្នឹង?

ហេនៈ ជឿ! ព្រោះអីយកទៅបាត់សូន្យ អត់ឃើញមកវិញខ្ញុំថាច្បាស់ជាមានងាប់ហើយ ។

ដានី: ចុះគេយកទៅហ្នឹង គេមានប្រាប់ថាម៉េចខ្លះដែរ?

ហេនៈ គេអត់មានប្រាប់យើងទេ មកហៅទៅម៉ង ។

ដានី: ចុះអ្នកដែលនៅថា មេទៅបាត់ហ្នឹងទៅធ្វើអីៗ គេអត់មានប្រាប់យើងទេ?

ហេនៈ គេអត់មានប្រាប់យើងទេ ។

ដានី: អីចឹងដល់ពេលបាត់ៗអីចឹងមីងសន្និដ្ឋានថាគេយកទៅសម្លាប់?

ហេនៈ ចាស ។

ដានី: អាហ្នឹងយើងសន្និដ្ឋានខ្លួនយើងទេឬ?

ហេនៈ ចាស!សន្និដ្ឋានខ្លួនយើង ។

ដានី: ចុះដូចថាអ្នកដែលនៅមូលដ្ឋានដូចម៉ែឪ អីចឹងមីងអត់ដឹងថាសុខទុក្ខគាត់អីយ៉ាងម៉េចទេ?

ហេនៈ អត់! អត់មានដឹងអីទាំងអស់ ។

ដានី: ចុះមកដល់សព្វថ្ងៃហ្នឹងមីងមានដែលនិយាយរឿងរ៉ាវដូចថាមីងធ្លាប់បានឆ្លងកាត់ធ្វើជាកម្មករកាត់ដេរអីប្រាប់ដល់កូនចៅដែលកើតក្រោយៗហ្នឹងបានដឹងបានឮដែលអត់?

ហេនៈ ប្រាប់ដែរ! ប្រាប់កូនខ្ញុំហ្នឹងឲ្យខំរកស៊ីទៅ ដូចម៉ែពីមុនណារកស៊ីក៏មិនបាន ខំរកក៏មិនមានទៅណា បានតែមាស៊ីហ្នឹងយ៉ាប ដល់ម៉ោងគេហៅទៅស៊ី ស៊ីអី ស៊ីហ្នឹងគេទៅ ហើយសព្វថ្ងៃយើងខំ យើងមានយើងបានចង់ហូបអីយើងទិញហ្នឹងហូបទៅ ។

ដានី៖  ចុះដល់ពេលមីងនិទានរឿងរ៉ាវពីសម័យខ្មែរក្រហម ពីជីវិតមីងប្រាប់អ៊ីចឹង កូនចៅជឿដែរអត់?

ហេន៖  ជឿ ។

ដានី៖  ចំពោះមីង មីងគិតថារឿងរ៉ាវដែលកើតឡើងនៅក្នុងរបបខ្មែរក្រហមមីងធ្វើជាកម្មករកាត់ដេរ ហើយមានបងពីរនាក់បាត់បង់អ៊ីចឹងមីងគិតថា គួរតែចង់ចាំទុក ឬគួរតែបំភ្លេចចោលពីរបបខ្មែរក្រហមហ្នឹង?

ហេន៖  មិនបំភ្លេចចោលទេ! នៅចាំជានិច្ចអ៊ីចឹងម៉ង ព្រោះបងប្អូនមានហ្នឹងគេដែរបាត់អស់រលីញជួបតែការវិនាស មិនបានជួបជុំគ្នា ។

ដានី៖  មីង! មកដល់សព្វថ្ងៃហ្នឹងនៅតាមស្រុកភូមិយើងហ្នឹងដូចមីង មីងធ្លាប់ឮពត៌មានស្ដីពីការបង្កើតសាលាក្ដី ដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ដែលអត់ ដូចជាតាមទូរទស្សន៍ តាមវិទ្យុ ឬក៏អ្នកភូមិគេនិយាយ?

ហេន៖  ឮដែរ ។

ដានី៖  ឮថាម៉េចទៅ?

ហេន៖  ឮថាកាត់ទោសមេដឹកនាំខ្មែរក្រហមប្រល័យពូជសាសន៍ ។

ដានី៖  មីងឮតាមរយៈណា?

ហេន៖  វិទ្យុគេផ្សាយ ។

ដានី៖  មីងស្ដាប់ឮថាម៉េចទៅ ពេលស្ដាប់ឮថាមានកាត់កាត់ទោសមេដឹកនាំ ជាន់ខ្ពស់ខ្មែរក្រហមអ៊ីចឹងមីងយល់យ៉ាងម៉េចដែរ?

ហេន៖  យល់យ៉ាងម៉េច?

ដានី៖  ដូចថាការកាត់ទោសមេដឹកនាំខ្មែរក្រហមហ្នឹងវាមានប្រយោជន៍អីខ្លះឬក៏អត់ប្រយោជន៍ទេ?

ហេន៖  ខ្ញុំអត់សូវដឹងដែរ ។

ដានី៖  តាមចិត្តមីងណា មីងចង់ឲ្យមានការកាត់ទោសហ្នឹងដែរអត់?

ហេន៖  អាហ្នឹងស្រេចតែប្រជាជនទូទៅទាំងអស់គ្នាម៉ងទៅ ។

ដានី៖  បាទ! ចុះចំពោះមីងផ្ទាល់?

ហេន៖  មីងក៏មានចិត្តខ្លះដែរ ។

ដានី៖ ចិត្តយ៉ាងម៉េចទៅ?

ហេន៖ ចង់ឲ្យគាត់ទោសអីចឹងដែរព្រោះអីវាបែកបាក់បងប្អូនអស់រលីញទៅហើយ ។

ដានី៖ អីចឹងខ្ញុំចង់បញ្ជាក់ប្រាប់មីងមួយសារទៀតថា ពួកខ្ញុំមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា មជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹង ធ្វើការទាក់ទងហ្នឹងការប្រមែរប្រមូលឯកសារក្នុងរបបខ្មែរក្រហម ដើម្បីចងក្រងទុកជាឯកសារប្រវត្តិសាស្ត្រ ពីរបបខ្មែរក្រហម ទុកឲ្យក្មេងៗជំនាន់ក្រោយ អ្នកសិក្សាស្រាវជ្រាវ ដែលគេចង់ដឹង គេចង់យល់ពីរបបខ្មែរក្រហមហ្នឹង គេអាចទៅអាន ទៅស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹងបាន ។ ហើយខ្ញុំមកដល់ផ្ទះមីងហ្នឹង គឺដោយសារខ្ញុំមានប្រវត្តិរូប បងមីងគាត់ឈ្មោះ ហឿន ណា ប្រវត្តិរូបរបស់គាត់ គឺគេដាក់ថា ប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំងនៅមន្ទីរស-២១ នៅទួលស្លែង អីចឹងគាត់មានដាក់ស្រុកកំណើត ដាក់ឈ្មោះឪពុកម្តាយអីចឹងខ្ញុំមកដល់ផ្ទះហ្នឹងចង់បញ្ជាក់ថា ហ្នឹងពិតជាឪពុកម្តាយ គាត់ថាស្រុកកំណើតហ្នឹងពិតប្រាកដមែនដែលអត់ អីចឹងប្រវត្តិរូបរបស់គាត់ ខ្ញុំជូនមីងទុកក្រែងលោបងប្អូនញាតិមិត្តអីគេចង់អាន ចុះពេលដែលពួកខ្ញុំមកសួរនាំរឿងរ៉ាវរបស់បងមីងអីចឹង ក្នុងចិត្តមីង មីងយល់យ៉ាងម៉េចដែរ?

ហេន៖ មិនយល់យ៉ាងម៉េចទេ ។

ដានី៖ មីងយល់យ៉ាងម៉េចដែរ?

ហេន៖ យល់ថាបងស្លាប់ហើយ អានេះដូចថាស្លាប់ហើយអានេះ នៅតែប្រវត្តិរូបទេ ។

ដានី៖ បាទ! ខ្ញុំអត់បានដឹងពិតប្រាកដថាគាត់យ៉ាងម៉េចដែរ ប៉ុនយើងមានតែប្រវត្តិរូបដែលបន្សល់ទុកពីរបបខ្មែរក្រហមមកណា បាទ! គាត់ជាប់គុកទួលស្លែង ចូលនៅថ្ងៃទី១៨ ខែ២ ឆ្នាំ៧៧ ។ អីចឹងមីងមានអីចង់បញ្ជាក់បន្ថែមនូវអ្វីដែលខ្ញុំអត់ទាន់បានសួរនាំមីង ចំពោះរឿងរ៉ាវប្រវត្តិសាស្ត្រខ្មែរក្រហមហ្នឹងដែរអត់? មានចង់បញ្ជាក់បន្ថែមអីទៀតដែរអត់?

ហេន៖ ចង់បញ្ជាក់ថាប្រវត្តិរូបនេះបានយកមកឲ្យខ្ញុំដឹង ខ្ញុំអរគុណមានចិត្តត្រេកអរ អរគុណដែលបានដឹងប្រវត្តិរូបហ្នឹង ។

ដានី៖ បាទ! អីចឹងខ្ញុំអរគុណមីងដែរ!

ហេន៖ ចាស ។

**ចប់**